តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ៖ ២០៧
ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩
សាលដីកា
លេខ៖ ២២៧
ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១

## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម ៖

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៦០"ខ" ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ២០៧ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់តុលាការកំពូល។

__ត្រូវចោទពីបទ៖__ ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិដើមដូង ឃុំមោង ស្រុកមោងឬស្សី ខេត្តបាត់ដំបង កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា១៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-ជនជាប់ចោទឈ្មោ [redacted] "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរកម្មកររើសែង កើតនិងរស់នៅភូមិដើមដូង ឃុំមោង ស្រុកមោងឬស្សី ខេត្តបាត់ដំបង ឪពុកឈ្មោ [redacted] " ម្តាយឈ្មោ [redacted] " នៅរស់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៦ ឃុំខ្លួនថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៦។

-មេធាវីលោ [redacted]

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] "ជាចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ២៨ឆ្នាំ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃនៅភូមិដូង ឃុំមោង ស្រុកមោងឬស្សី ខេត្តបាត់ដំបង ។

-ជនរងគ្រោះឈ្មោះ [redacted] ភេទស្រី អាយុ៦ឆ្នាំ ។

កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៦ វេលាម៉ោង៦ព្រឹក ខ្លួនលក់ដូរ ប្តីទៅរត់រទេះសេះ ក៏ផ្ញើកូន [redacted] ហៅ ត្រយ៉ោល អាយុ៦ឆ្នាំ ជាមួយជីតា ស្រាប់តែ [redacted] បួលកូនខ្លួនទៅលេងធ្វើខ្មោច មានក្មេងប្រុស [redacted] អាយុ៥ឆ្នាំ ទៅលេងជាមួយដែរ។ ពេល



Scanned by CamScanner

នោះ [redacted] ចាប់កូនខ្លួនរំលោភដោយគំរាម [redacted] បើប្រាប់ម៉ែឪវាសម្លាប់ចោល ឯកូនខ្លួនក៏ត្រូវគំរាមថា បើហ៊ាននិយាយប្រាប់គេ វាចាប់ដាក់ក្នុងអណ្តូងលូឲ្យងាប់។ លុះស្អែកថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៦ ឈ្មោះ [redacted] បបួលកូនខ្លួនទៅកន្លែងដដែល ហើយ [redacted] រត់មកប្រាប់ខ្លួនថា ពួកឯង កំពុងទាញដៃបបួលមី ត្រងោល ទៅលេងចុយគ្នាទៀតហើយ ខ្លួនទៅទាញដៃកូនមកវិញ អាកង ក៏រត់បាត់។ ពេលខ្លួនដឹងភ្លាម ក៏ទៅប្តឹងមេភូមិ និងប៉ូលីស ។ ហើយកូនខ្លួនបានប្រាប់ថាពេល [redacted] លោភ វាយកដៃច្របាច់ក និងយកអាវញាត់មាត់ គំរាមមិនឲ្យស្រែក ហើយខ្លួនក៏ពិនិត្យប្រដាប់ភេទកូនឃើញមានសភាពញែក ជាំ ខ្លួនក៏នាំកូនទៅពិនិត្យនៅមន្ទីរពេទ្យធំខេត្តបាត់ដំបង ប៉ុន្តែគ្រូពេទ្យពុំបានផ្តល់វិញ្ញាបនប័ត្រឲ្យទេ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ជាះចោទប្រកាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ២០ឆ្នាំ ពីបទ ប៉ុនប៉ងរំលោភ សេពសន្ថវៈ ប្រព្រឹត្តនៅភូមិដើមដូង ឃុំមោង ស្រុកមោង ឫស្សី ខេត្តបាត់ដំបង កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៦។ តាមមាត្រា៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៨៩-ខ- ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្តបាត់ដំបង ដែលបានសំរេចៈ

១-អោយឈ្មោះ [redacted] ភេទប្រុស អាយុ២២ឆ្នាំ រួចផុតពីបទចោទ ប៉ុនប៉ងរំលោភសេពសន្ថវៈ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៦ នៅភូមិដើមដូង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។ ក្នុងដីកាសន្និដ្ឋានស្ថាពរលេខ៦៩១ ដស.ណស ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៦ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តបាត់ដំបង និងដីកាបញ្ជូនរឿងអោយជំរះលេខ ២៧៨៦ ណស-ព្រទ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៦ របស់ចៅក្រមស៊ើបអង្កេត ។

-តាមគោលការណ៍នៃច្បាប់ព្រហ្ម

-តាមមាត្រា១៥២ នៃច្បាប់ស្តីពីនិតិវិធីព្រហ្មទណ្ឌ

២-បង្គាប់ឈ្មោះ [redacted] ជាអ្នកអាណាព្យាបាលលើឈ្មោះ [redacted] ចេញសំណងជំងឺចិត្តឲ្យដល់ឈ្មោះ [redacted] ជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន១លានរៀល។ ដើមបណ្តឹងរដ្ឋប្បវេណីទារលើសពីនេះបដិសេធចោល។

-តាមមាត្រា១២១, ១២៣ និង១២៤ នៃក្រឹត្យច្បាប់លេខ៣៨ក្រច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨។

៣-សាលក្រមនេះ ជំនុំជំរះជាសំងាត់និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ គិន សុខកង និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីនិងអ្នកអាណាព្យាបាលលើ [redacted] ទុករយៈពេលប្តឹងទាស់និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៧៩ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៦ របស់លោ [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តបាត់ដំបង ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៨៩-ខ- ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថាៈ តាមចម្លើយរបស់ជនជាប់ចោទ ដែលបានឆ្លើយនៅដំណាក់កាលសួរយកចម្លើយនៅនគរបាល អយ្យការ



Scanned by CamScanner

និងចៅក្រមស៊ើបអង្កេត បានសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តមែន គឺរំលោភសេពសន្ថវៈទៅលើជនរងគ្រោះឈ្មោះ [redacted] ប្រាកដមែន ការដែលចៅក្រមជំនុំជំរះសម្រេចឲ្យជនជាប់ចោទពុំមានលក្ខណៈត្រឹមត្រូវទេ គប្បីធ្វើប្រតិកោសល្យវិច័យដល់ថ្នាក់ជាតិ ដើម្បីបញ្ជាក់លើខួរក្បាលសសៃប្រសាទ តើមានជំងឺវិកលចរិក ឬ យ៉ាងណា សូមឯកឧត្តមប្រធានពិនិត្យ និងពិចារណា ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៦០-ខ- ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ៧៩ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៦ របស់លោកព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-បដិសេធចំណុចទី១នៃសាលក្រមព្រហ្មទណ្ឌលេខ៨៩-ខ-ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៦ របស់តុលាការខេត្តបាត់ដំបង ចោលជាអសារបង់ក្រៅពីនេះទុកនៅដដែល។

៣-កែប្រែបទចោទប្រកាន់លើជនជាប់ចោទ ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈទៅជាបទរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិដើមដូង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋវិញ។

៤-ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករលីសែងលំនៅកំណើត និងលំនៅសព្វថ្ងៃនៅភូមិដើមដូង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ដាក់ពន្ធនាគារកំណត់១៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៦ ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិដើមដូង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង តាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៥-បង្គាប់ឲ្យបន្តការឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារជនជាប់ចោទ បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១០០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ របស់លោក [redacted] មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៦០-ខ- ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការតុលាការកំពូលថា៖

+បណ្តឹងសាទុក្ខរបស់លោក [redacted] ជាមេធាវីការពារឲ្យឈ្មោះ [redacted] ធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិចារណាបានតាមមាត្រា១៨ នៃច្បាប់ស្តីពីការរៀបចំ និងសកម្មភាពនៃសាលាជំរះក្តី។

+មានកស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទ [redacted] ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិដើមដូង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៦ តាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។



Scanned by CamScanner

+សាលដីកាព្រហ្មទណ្ឌលេខ៦០-ខ- ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ដែលសំរេចមកនេះពុំទាន់ត្រឹមត្រូវតាមច្បាប់ឡើយ។

អាស្រ័យហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេច។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោ[redacted]មេធាវីការពារអោយជនជាប់ចោទឈ្មោះ[redacted]នាពេលសវនាការថា៖ ការសំរេចសេចក្តីចោទមកលើកូនក្តីខ្ញុំបាទ គឺមិនត្រឹមត្រូវទេ គាត់ប្រព្រឹត្តឡើងតែមិនបានឈានដល់ការសំរេចនោះទេ ព្រោះគាត់មានស្មារតីមិនល្អ ហើយមានការបញ្ជាក់ពីមន្ទីរពេទ្យថា កូនក្តីខ្ញុំបាទមានបញ្ហាទៅលើស្មារតី (ឆ្កួតវង្វេងលីលឺ) ហើយមានការបញ្ជាក់ពីលោក[redacted]នៅក្នុងពន្ធនាគារថា កូនក្តីខ្ញុំបាទមិនអាចឃុំខ្លួនបានទេ ព្រោះនៅក្នុងឃុំគ្មានដេកពួនទេ គិតតែស្រែឡូឡា។

សំណូមពរ៖ សូមដោះលែងកូនក្តីខ្ញុំបាទអោយមានសេរីភាពវិញ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារអោយជនត្រូវចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

-យល់ឃើញថា៖ បណ្តឹងសាទុក្ខលេខ១០០ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ របស់លោក ប៊ុន រិទ្ធី មេធាវីរបស់ជនត្រូវចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៨ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៦០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា៖ ដោយក្រមព្រហ្មទណ្ឌបានចូលជាធរមាន ហើយបទល្មើសនេះការកំណត់ទណ្ឌកម្មក្នុងព្រហ្មទណ្ឌមានលក្ខណៈស្រាលជាងច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ គប្បីអនុវត្តមាត្រា១០ នៃក្រមព្រហ្មទណ្ឌ។

-យល់ឃើញថា៖ សាលដីកាសភាព្រហ្មទណ្ឌលេខ៦០-ខ- ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះពុំមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ទេ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ១០០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ របស់លេ[redacted] មេធាវីរបស់ជនត្រូវចោទ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់។

២-បដិសេធសាលដីកាសភាព្រហ្មទណ្ឌលេខ៦០-ខ- ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ចោលជាអសារបង់។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ២០៧ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះសាជាថ្មីឡើងវិញ។



Scanned by CamScanner

៩-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២

ក្រឡាបញ្ជី

[redacted]

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២

ជ. ប្រធានតុលាការកំពូល

អនុប្រធាន



Scanned by CamScanner